# អារម្ភកថា

ក្រុបខ័ណ្ឌសកម្មភាពក្រុងដាកាអនុម័តនៅវេទិកាអប់រំពិភពលោកនៅក្រុងដាកាឆ្នាំ ២០០០ បានប្រកាសយ៉ាងច្បាស់ថា ការអប់រំជាគ្រឹះនៃសិទ្ធិមនុស្ស ហើយបានគូសបញ្ជាក់យ៉ាងច្បាស់អំពីសារៈសំខាន់នៃសកម្មភាពរបស់រដ្ឋាភិបាលដោយយកសិទ្ធិមនុស្សជាមូលដ្ឋានបង្អែកក្នុងការសំរេចគោលដៅអប់រំសំរាប់ទាំងអស់គ្នា។ អង្គការយូណេស្កូ គាំទ្រទស្សនៈ និងជំហរដែលយកសិទ្ធិមនុស្សធ្វើជាមូលដ្ឋានបង្អែកសំរាប់អភិវឌ្ឍវិស័យអប់រំដែលជាជំហានដំបូងសំរាប់ការអប់រំសំរាប់ទាំងអស់គ្នា។

ការិយាល័យអប់រំរបស់អង្គការយូណេស្កូប្រចាំតំបន់អាស៊ីប៉ាស៊ីភិចនៅបាងកកសូមបង្ហាញជូននូវសៀវភៅនេះ។ សៀវភៅនេះចងក្រងរាល់កិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់អង្គការយូណេស្កូក្នុងការអភិវឌ្ឍន៍គោលនយោបាយធានាសំរេចការអប់រំដោយឈរលើសិទ្ធិមនុស្សជាមូលដ្ឋាន។ សៀវភៅនេះត្រូវបានរៀបរៀងឡើងក្នុងច្បាប់ដើមដោយ Katarina Tomasevski ជាឯកសារមូលដ្ឋានសំរាប់សិក្ខាសាលាតំបន់ស្តីពី *សកលកម្មសិទ្ធិទទួលការអប់រំប្រកបដោយគុណភាព : វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សដើម្បីសំរេចការអប់រំសំរាប់ទាំងអស់គ្នា* នៅទីក្រុងម៉ានីឡា ប្រទេសភីលីពីនកាលពីថ្ងៃ ២៩–៣១ តុលា ឆ្នាំ ២០០២។

នៅទូទាំងពិភពលោកការយល់ដឹង និងការឯកភាពគ្នាជារួមដែលថា មន្ត្រីរដ្ឋាភិបាល ភ្នាក់ងារអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលពិតជាត្រូវការជំនួយយ៉ាងធំធេងក្នុងការធានាថា រាល់បញ្ញត្តិទាំងអស់ដែលមានចែងនៅក្នុងសិទ្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិត្រូវយកមកឆ្លុះបញ្ចាំងក្នុងគោលនយោបាយអប់រំហើយបញ្ចូលទៅក្នុងប្រព័ន្ធអប់រំតាមប្រទេស។ ទាំងក្របខ័ណ្ឌសកម្មភាពក្រុងដាកា និងកាតព្វកិច្ចសិទ្ធិមនុស្សបានកំណត់រកឃើញតម្រូវការមួយគឺ ការអប់រំដោយឥតបង់ថ្លៃ និងដោយកាតព្វកិច្ច ដែលមានគុណភាពសំរាប់កុមារគ្រប់រូប។ ប៉ុន្តែ ដើម្បីសំរេចគោលដៅដ៏ចំបងនេះត្រូវជួបប្រទះការលំបាកច្រើនណាស់។

សៀវភៅនេះមានបំណងកំណត់រកឲ្យឃើញនូវបញ្ញត្តិ និងខ្លឹមសារបច្ចេកទេសមួយចំនួនដែលមានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយសំខាន់ជាងនេះទៀត សៀវភៅនេះជាឯកសារយោងដ៏មានប្រយោជន៍មួយសំរាប់អ្នកដែលមានបំណងចង់ស្វែងយល់ឲ្យកាន់តែស៊ីជំរៅអំពីបញ្ញត្តិនានាទាក់ទងនឹងសិទ្ធិទទួលការអប់រំ។ និយាយដោយសង្ខេប និងវិភាគអំពីសន្ធិសញ្ញា និងអនុសញ្ញាសិទ្ធិមនុស្សសំខាន់ៗដោយឈរលើទស្សនៈអប់រំ សៀវភៅនេះលើកឡើងអំពីសិទ្ធិគន្លឹះៗ ដែលទាក់ទងនឹងកុមារ ឪពុកម្តាយ រដ្ឋាភិបាល ហើយសៀវភៅនេះក៏លើកឡើងអំពីកាតព្វកិច្ចស្របគ្នា ជាពិសេស កាតព្វកិច្ចរបស់រដ្ឋាភិបាលដែលត្រូវបំពេញដើម្បីធានាផ្តល់សិទ្ធិឲ្យបានជោគជ័យផងដែរ។

គោលបំណងរបស់សៀវភៅនេះគឺសំដៅបង្ហាញជូននូវការណែនាំមួយដែលងាយយល់អំពីយុទ្ធសាស្ត្រអប់រំដោយយកសិទ្ធិមនុស្សជាមូលដ្ឋាន ដោយបានដកស្រង់បទពិសោធន៍មកពីប្រទេសជាច្រើន និងចំណេះដឹងពីឯកសារសិទ្ធិមនុស្សសកលលោកជាច្រើនទៀត។

យើងសង្ឃឹមថា សៀវភៅនេះនឹងក្លាយជាឯកសារដ៏មានប្រយោជន៍សំរាប់កិច្ចខិតខំប្រឹងប្រែងរបស់ពិភពលោកដើម្បីអនុវត្តយុទ្ធសាស្ត្រអប់រំដោយយកសិទ្ធិមុស្សជាមូលដ្ឋានបង្អែក និងដើម្បីលើកកំពស់សិទ្ធិទទួលការអប់រំ ដែលយុទ្ធសាស្ត្រទាំងពីរនេះសុទ្ធតែមានសារៈសំខាន់ក្នុងការធានាសំរេចការអប់រំសំរាប់ទាំងអស់គ្នា។



Sheldon Shaeffer
Director UNESCO Bangkok